# ៥

# ប្រយោជន៍ នៃ ធម៌ អនត្តា

**សព្វេ ធម្មា អនត្តា** មានន័យថា ធម៌ទាំងឡាយ ទាំងពួង មិនមែន ជា របស់យើង

ក្នុងន័យនេះ ដោយ ខន្ធ៥ ក៏ជាធម៌ដែរ ដូច្នេះ ខន្ធ៥ ក៏មិនមែនជារបស់យើងគ្រប់គ្នាដែរ។ ហេតុអ្វីក៏ថាមិនមែនជារបស់យើង ពីព្រោះ ព្រះពុទ្ធសាសនាដែលយកច្បាប់ធម្មជាតិជាគោល សង្កេតឃើញថាធម្មជាតិ មានលក្ខណៈបី គឺ៖ **អនិច្ចំ ទុក្ខំ អនត្តា** ។ **អនិច្ចំ** មានន័យថា មិនទៀង ។ ដូច្នេះ ខន្ធ៥ នៅក្នុងធម្មជាតិ ក៏មិនទៀងដែរ ហើយបើ ខន្ធ៥ មិនទៀង តើយើងអាចទុកខន្ធ៥ ថាជារបស់យើងបានទេ បើមិនដឹងជាថ្ងៃណាផង វានឹងបែកធ្លាយទៅវិញនោះ។ តើលក្ខណៈ **អនិច្ចំ** ចេញមកពីណា ? ចម្លើយ គឺចេញមកពី ភាវៈ [**កើត-រលត់ កើត-រលត់**] ជានិច្ច នៃសង្ខារធម៌ទាំងពួង ។ សព្វថ្ងៃនេះ អ្នកវិទ្យាសាស្ត្រក៏គេយល់ស្របនូវ ភាវៈនេះដែរ ។ ខ្ញុំសូមជូនឧទាហរណ៍ខ្លះនូវ លក្ខណៈមិនទៀង និង លក្ខណៈ កើត-រលត់ ដូចតទៅ៖

<u>**លក្ខណៈមិនទៀង**</u> ដូចជា ធាតុអាកាស ម្តងក្តៅ ម្តងត្រជាក់ អ្នកខ្លះធ្លាប់មានទ្រព្យសម្បត្តិ បុណ្យសក្តិធំ ស្រាប់តែធ្លាក់ខ្លួនមកក្រវិញក៏មាន ។ បើមិនទៀងរបៀបនេះ តើមានការកក់ក្តៅ ទុកចិត្តម្តេចនឹងកើត ។ ម្យ៉ាងទៀតដោយនឹកថា ខ្លួន ជារបស់អញម្នាក់ៗទៅជាមានការ លោភលន់ ចង់បានមិនចេះឆ្អែតឆ្អន់ ហើយជាប់ជំពាក់នឹងទ្រព្យសម្បត្តិ បុណ្យសក្តិ លាភ យស សេចក្តីសុខ ។ ចង់ឲ្យគេ គោរព សរសើរ ខ្លួន តែ រំលោភលើច្បាប់ លើសុជីវធម៌ កំហែងអ្នកទន់ខ្សោយ ខ្វះធម៌មេត្តា ។ នេះមកតែពី គិតថា ខ្លួនជារបស់ខ្លួន កូនប្រពន្ធជារបស់ខ្លួន ហើយដោយអ្នកដទៃ មិនមែនជា

កូនចៅ ជាមិត្តសម្លាញ់ខ្លួន ក៏ធ្វើបាបរំលោភគេទៅ ។

តែការពិត មាន កូនចៅ មិត្តសម្លាញ់របស់ខ្លួនឯណា បើខ្លួនឯងមិនមែនជារបស់ខ្លួនឯងផង មិនដឹងជាស្លាប់[1] ថ្ងៃណាផង។ ប្រសិនបើជាមនុស្សលោកទាំងអស់គ្នា យកធម៌មិនទៀងនេះ ដាក់ក្នុងចិត្ត នោះពិភពលោកយើងនេះ បានសេចក្តីសុខសប្បាយ ឥតមានសង្គ្រាមរវាង ប្រទេសនិងប្រទេស ឬ ការវិវាទរវាង បុគ្គល និង បុគ្គលសោះឡើយ ។ ម្យ៉ាងទៀតដោយថាជីវិតមិនទៀង បើយើងជឿនូវកម្មផល នោះយើងខំធ្វើអំពើល្អ ខំសន្សំកុសលទុកឲ្យបានច្រើនសម្រាប់ជាតិខាងមុខ ទាន់យើងនៅរស់ ហើយអាចធ្វើដោយខ្លួនឯងបាន ដោយមិនចាំបាច់ពឹង កូនចៅឲ្យធ្វើបញ្ជូនកុសលទៅតាមក្រោយ ។

**<u>លក្ខណកើត-រលត់</u>** ដូចជា [ វេទនាក៏កើតរលត់ ] [ដង្ហើមចូល និងដង្ហើមចេញ ] [ ចិត្ត ] [ ចិត្តចុតិរលត់ ចិត្តបដិសន្ធិក៏កើត ] ជាដើម ។

មនុស្សយើងម្នាក់ៗ មាន កាយនិងចិត្ត ៖ កាយក៏កើតរលត់ ចិត្តក៏កើតរលត់ ។

កាយកើតរលត់ ដូចជា កាលណាយើងដកដង្ហើម ខ្យល់ចូលគឺកើត ខ្យល់ចេញគឺរលត់។ ដែលយើងហៅថាជីវិត គឺការផ្សំគ្នារវាងថាមពលកាយនិងថាមពលចិត្ត។ ថាមពលនោះផ្លាស់ប្តូរជានិច្ច វាមិនដូចគ្នាពីពេលមួយ ទៅពេលបន្ទាប់នោះទេ។ គឺវាកើត ហើយវារលត់ទៅវិញភ្លាម មុននឹងកើតជាថ្មី និងរលត់ជាថ្មីម្តងទៀត ហើយចេះតែតៗ ជាវៀងដរាបទៅ រហូតដល់ដង្ហើមចុងក្រោយ ហៅថា ចុតិចិត្ត។ តែបន្ទាប់ពីចុតិចិត្តរលត់ទៅ បដិសន្ធិចិត្តក៏

[1] ដល់ពេលស្លាប់ គឺខ្លួនទីពឹងខ្លួនហើយ មិត្តភក្តិ ប្រពន្ធកូនជួយមិនបានទេ ទ្រព្យសម្បត្តិលុយកាក់ តែមួយកាក់យកទៅមិនបានផង ដូចជំនាន់ដើម គេដាក់ក្នុងមាត់មនុស្សស្លាប់ ប្រាក់មួយកាក់ ហើយដល់ពេលគេបូជាសពរួចហើយ ប្រាក់កាក់នោះនៅដដែល ។ នេះសម្រាប់ឲ្យយើងពិចារណា ថា ស្លាប់ទៅទ្រព្យសម្បត្តិយកទៅមិនរួចទេ ដូច្នេះត្រូវរកស៊ីដោយសម្មាអាជីវោ ។

កើតជាបន្តគ្នាភ្លាមមិនបានឃើតយូរឡើយ ។ ហេតុនេះចិត្ត កើតរលត់ កើតរលត់ តៗគ្នា ពីជាតិមួយទៅជាតិមួយ មិនដែលដាច់ទេ ទាល់តែឈប់កើត គឺទាល់តែសម្រេចនិព្វាន ទើបចប់ការកើតការរលត់នៃចិត្ត ។ បើតាមន័យនេះ ដោយ ខន្ធ៥ កើតរលត់ កើតរលត់ ដូច្នេះការរស់នៅនៃយើងសព្វថ្ងៃនេះ ក៏ដូចជា ស្លាប់កើត ស្លាប់កើតដែរ ហើយ បើនិយាយឲ្យអស់សេចក្តី គឺ **កើត តាំងនៅ ហើយរលត់ទៅ** ចេះតែ តៗ រហូតដល់ សេចក្តីស្លាប់ចុងក្រោយ ។ ការកើតនៅភពថ្មី ខុសពីការរស់នៅសព្វថ្ងៃនេះ ត្រង់កាយ ស្លាប់ តែចិត្តកើតបន្តពីចិត្តចុតិ ។ ដូច្នេះ កុសលកម្ម និង អកុសលកម្ម ដែលយើងបាន សន្សំទុកពីមុនមក អត់បាត់ទៅណាទេ ច្បាប់កម្មផល ទុកឲ្យយើងទាំងអស់ យើងយកទៅ តាមពីមួយជាតិទៅមួយជាតិ ។ ដូចជាព្រះពុទ្ធមិនមែនទើបតែសាងមួយ ជាតិចុងក្រោយ នេះ ហើយក៏បានត្រាស់ជាព្រះពុទ្ធនោះទេ ។ តាមជាតក ព្រះអង្គបានសន្សំកុសល ជាច្រើនជាតិ រាប់មិនអស់ មុននឹងបានសម្រេចមគ្គផលនិព្វាន ។

បើយើងជឿតាមទ្រឹស្តីនេះ យើងត្រូវខំសន្សំកុសល គ្រប់ៗជាតិ ជាមួយគ្នានេះ យើងខំ បន្ថយអំពើអកុសលទាំងឡាយ ដែលហាមដោយច្បាប់រដ្ឋ ឬដោយ ច្បាប់សាសនា។ ជាទូទៅ ក្នុងមុខវិជ្ជានីមួយៗ មានពីរផ្នែក គឺផ្នែកទ្រឹស្តី និងផ្នែក ការអនុវត្តន៍ ពីព្រោះថា ដើម្បីទាញយកផលប្រយោជន៍ ពីទ្រឹស្តីនោះបាន ទាល់តែយើងយកទ្រឹស្តីនោះមកប្រើ មកធ្វើការពិសោធន៍ ។ ដូចនៅក្នុងគណិតសាស្រ្ត កាលនៅពីក្មេង យើងខំទន្ទេញ មេលេខឲ្យរត់មាត់ ដូចជា ៖ ពីរ ពីរដង បួន (២ x ២ = ៤) និង ពីរ បីដង ប្រាំមួយ ជាដើម ។ ហើយដល់ការអនុវត្តន៍ គឺការគិតលេខ ក្នុងចំណោទ្យ ដូចជា ៖ ខ្មៅ ដៃមួយ ថ្លៃ ២ រៀល តើខ្មៅដៃ ៣ ថ្លៃប៉ុន្មាន ? នៅក្នុងធម៌ព្រះពុទ្ធ បើយើងគ្រាន់តែយល់ ទ្រឹស្តី ហើយយើងមិនខំអប់រំចិត្តទៅតាមទ្រឹស្តីនោះទេ យើងក៏ មិនអាចទទួលផលពីទ្រឹស្តី ព្រះអង្គបានដែរ ។ ដូចនៅក្នុងសីល ៥ មានវៀរ ការសម្លាប់សត្វ ការសេពសុរា ។តែលោក

អ្នកខ្លះ នៅតែ សម្លាប់សត្វ នៅតែផឹកស្រា ដដែល ថ្វីបើយល់ថា សត្វក៏គ្នាចង់មានជីវិត ស្រឡាញ់ជីវិតដូចតែយើងដែរ ។ រួមសេចក្តីទៅ យើងត្រូវ ខំអប់រំចិត្ត តទៅទៀត ដោយ យកធម៌ព្រះពុទ្ធជាគោល ដើម្បីនឹងបានផលប្រយោជន៍ដល់យើង ទៅអនាគត ។